# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៣០៩ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការរៀបចំនិងការប្រព្រឹត្តទៅនៃ
## ក្រុមប្រឹក្សាធនាភិបាលសន្តិសុខសង្គមនៃបេឡាជាតិសន្តិសុខសង្គម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥២០/៥៨២ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០ ស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គម ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២២១ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ១៩៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.)
- បានឃើញអនុក្រឹត្យលេខ១៦០ អនក្រ.បក ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០២២ ស្តីពីនិយ័តកម្មប្រព័ន្ធសន្តិសុខសង្គម
- បានឃើញអនុក្រឹត្យលេខ៤៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ ស្តីពីគោលការណ៍ណែនាំសម្រាប់ការវិនិយោគមូលនិធិសន្តិសុខសង្គម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .–**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធនាភិបាលសន្តិសុខសង្គមនៃបេឡាជាតិសន្តិសុខសង្គម ដែលសរសេរជាអក្សរកាត់ថា **ក.ធ.ស**. ដើម្បីគ្រប់គ្រងកិច្ចការវិនិយោគមូលនិធិរបស់ផ្នែកនីមួយៗនៃរបបសន្តិសុខសង្គម សំដៅធានាឱ្យបាននូវនិរន្តរភាពមូលនិធិសន្តិសុខសង្គមប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

**មាត្រា២ .–**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តលើកិច្ចការវិនិយោគមូលនិធិសន្តិសុខសង្គម និងការគ្រប់គ្រងមូលនិធិសន្តិសុខសង្គមរបស់បេឡាជាតិសន្តិសុខសង្គម (**ប.ស.ស.**)។

**មាត្រា៣ .–**

បច្ចេកសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចតទៅ៖

១- **ញាតិពន្ធ** សំដៅដល់ចំណងគតិយុត្តរវាងសហព័ទ្ធម្ខាង និងញាតិលោហិតរបស់សហព័ទ្ធម្ខាងទៀត (សាច់ថ្លៃ)។

២- **ញាតិលោហិត** សំដៅដល់ញាតិដែលមានឈាមជ័រជាមួយគ្នា ដូចជា ឪពុកនិងកូន ឬម្តាយនិងកូន ជាដើម។

៣- **តតិយជន** សំដៅដល់ជនទីបី ឬជនដែលមិនមែនជាភាគីនៅក្នុងទំនាក់ទំនងគតិយុត្ត។

៤- សាខាញាតិ សំដៅដល់ញាតិដែលបែកចេញជាមែកជាងពីអ្នកបង្កើតរួម ដូចជា បងប្អូនបង្កើត មីងមាក្មួយ បងប្អូនជីដូនមួយ។

៥- សហព័ទ្ធ សំដៅដល់ប្តី ឬប្រពន្ធ ឬទាំងប្តីទាំងប្រពន្ធដែលទទួលបានឋានៈជាសហព័ទ្ធនេះក្រោយពីបានចុះបញ្ជីអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់។

## ជំពូកទី២

## តួនាទីនិងភារកិច្ចរបស់ គ.ធ.ស.

**មាត្រា៤ .-**

**គ.ធ.ស.** មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ពិនិត្យនិងរៀបចំគោលការណ៍នៃការគ្រប់គ្រងមូលនិធិសម្រាប់ការវិនិយោគ
- ពិនិត្យនិងរៀបចំផែនការវិនិយោគប្រចាំឆ្នាំ
- ពិនិត្យនិងរៀបចំផែនការធ្វើពិពិធកម្មហានិភ័យសម្រាប់ការវិនិយោគ
- ពិនិត្យនិងរៀបចំរបាយការណ៍វាយតម្លៃសមិទ្ធកម្មប្រចាំឆ្នាំ
- ពិនិត្យនិងរៀបចំគម្រោងវិនិយោគរយៈពេលខ្លី មធ្យម និងវែង
- ទទួលបន្ទុកគ្រប់គ្រងនិងចាត់ចែងកិច្ចការវិនិយោគក្នុងវិស័យសាធារណៈនិងឯកជន ព្រមទាំងការពិនិត្យនិងតាមដានទ្រព្យសម្បត្តិដែលបានមកពីការវិនិយោគ
- ពិនិត្យនិងរៀបចំយុទ្ធសាស្ត្រវិនិយោគរយៈពេលខ្លី មធ្យម និងវែង ស្របតាមគោលនយោបាយវិនិយោគសាធារណៈរបស់រាជរដ្ឋាភិបាល
- រៀបចំនិងស្នើសុំចេញនូវលិខិតបទដ្ឋានគតិយុត្តនានាដើម្បីគាំទ្រដល់ការវិនិយោគរបស់ **ប.ស.ស.**
- កំណត់លំដាប់អាទិភាពនៃកម្មវិធីវិនិយោគ
- ពិនិត្យនិងរៀបចំរបាយការណ៍វិនិយោគរបស់ **ប.ស.ស.**
- ពិនិត្យនិងរៀបចំរបាយការណ៍ស្តីពីការរក្សានិងការគ្រប់គ្រងមូលនិធិសន្តិសុខសង្គមទាំងមូល
- ពិនិត្យនិងរៀបចំនីតិវិធីវាយតម្លៃការដាក់ជួល លក់ ដូរ និងផ្ទេរសិទ្ធិទ្រព្យសម្បត្តិដែលបានមកពីការវិនិយោគ
- ចូលរួមរៀបចំសេចក្តីសម្រេចពាក់ព័ន្ធនឹងទ្រព្យសម្បត្តិដែលបានមកពីការវិនិយោគ
- រៀបចំគោលការណ៍សម្រាប់ការគ្រប់គ្រងមូលនិធិ ការគ្រប់គ្រងការវិនិយោគ និងផែនការធ្វើពិពិធកម្មហានិភ័យ អនុលោមតាមគោលការណ៍ណែនាំស្តីពីការវិនិយោគរបស់និយ័តករសន្តិសុខសង្គម (**ន.ស.ស.**)
- ពិនិត្យនិងរៀបចំគោលការណ៍គ្រប់គ្រងមូលនិធិរបស់ផ្នែកនីមួយៗនៃរបបសន្តិសុខសង្គម។

## ជំពូកទី៣

## សមាសភាពរបស់ គ.ធ.ស.

**មាត្រា៥ .-**

**គ.ធ.ស.** មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - តំណាងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ប្រធាន |
| - តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប | សមាជិក |



9

- តំណាង **ប.ស.ស.** ១រូប សមាជិក
- តំណាងធនាគារជាតិនៃកម្ពុជា ១រូប សមាជិក
- តំណាងនិយោជក ២រូប សមាជិក
- តំណាងសមាជិក **ប.ស.ស.** ២រូប សមាជិក
- អ្នកជំនាញអព្យាក្រឹត្យឬឯករាជ្យ ៣រូប សមាជិក។

**គ.ធ.ស.** អាចមានសមាសភាពបន្ថែមជាសមាជិក ដែលជាតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត តាមការចាំបាច់។ សមាសភាពបន្ថែមត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល។

សមាសភាពជាក់ស្ដែងរបស់ **គ.ធ.ស.** ត្រូវតែងតាំងដោយសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៦ .-**

បេក្ខភាពសមាជិក **គ.ធ.ស.** ត្រូវបំពេញតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា១៤ នៃអនុក្រឹត្យលេខ៤៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ ស្ដីពីគោលការណ៍ណែនាំសម្រាប់ការវិនិយោគមូលនិធិសន្តិសុខសង្គម និងត្រូវ៖

- មានសញ្ជាតិខ្មែរ
- មិនត្រូវជាសហព័ទ្ធ ញាតិលោហិត សាខាញាតិ ឬញាតិពន្ធ នៃសមាជិក **គ.ធ.ស.** ឬក្រុមប្រឹក្សាភិបាល នៃ **ប.ស.ស.** ឡើយ។

បេក្ខភាពជាប្រធាន **គ.ធ.ស.** ត្រូវមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រជាន់ខ្ពស់ឡើងទៅ ពាក់ព័ន្ធនឹងជំនាញ គណនេយ្យ ឬហិរញ្ញវត្ថុ ឬសេដ្ឋកិច្ច ឬវិនិយោគ។

បេក្ខភាពដែលជាតំណាងនិយោជក និងតំណាងសមាជិក **ប.ស.ស.** ត្រូវជ្រើសរើសដោយអង្គការវិជ្ជាជីវៈ រៀងៗខ្លួន។

**មាត្រា៧ .-**

បេក្ខភាពសមាជិកអព្យាក្រឹត្យឬឯករាជ្យមិនត្រូវមានជាប់ពាក់ព័ន្ធនឹងសកម្មភាពនយោបាយ និងត្រូវបំពេញ តាមលក្ខខណ្ឌដូចមានកំណត់ក្នុងមាត្រា១៤ និងមាត្រា១៥ នៃអនុក្រឹត្យលេខ៤៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ ស្ដីពីគោលការណ៍ណែនាំសម្រាប់ការវិនិយោគមូលនិធិសន្តិសុខសង្គម។

បេក្ខភាពសមាជិកអព្យាក្រឹត្យឬឯករាជ្យនេះត្រូវដាក់ពាក្យស្នើសុំមកអគ្គនាយក **ប.ស.ស.** ដើម្បីពិនិត្យ និងដាក់ជូនក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស.** សម្រេចនិងដាក់ស្នើសុំការទទួលស្គាល់ពី **ឧ.ស.ស.**។

**មាត្រា៨ .-**

សមាសភាពរបស់ **គ.ធ.ស.** ត្រូវមានអាណត្តិ៣(បី)ឆ្នាំ។

សមាសភាពរបស់ **គ.ធ.ស.** ត្រូវបានបញ្ចប់មុនអាណត្តិ ក្នុងករណីសាមីខ្លួន៖

១- ទទួលមរណភាព។

២- មានវិបល្លាសស្មារតី។

៣- សុំលាឈប់ជាលាយលក្ខណ៍អក្សរ។

៤- បាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច។

៥- ត្រូវផ្ដន្ទាទោសស្ថាពរឱ្យជាប់ពន្ធនាគារពីបទមជ្ឈិមឬបទឧក្រិដ្ឋណាមួយ។

**មាត្រា៩ .-**

សមាសភាពរបស់ **គ.ធ.ស.** មានកាតព្វកិច្ចប្រកាសទ្រព្យសម្បត្តិរបស់ខ្លួនទៅអង្គភាពប្រឆាំងអំពើពុករលួយ ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៤
## ការប្រព្រឹត្តទៅរបស់ គ.ធ.ស.

**មាត្រា១០ .-**

**គ.ធ.ស.** ត្រូវមានរបបប្រជុំប្រចាំខែ និងប្រជុំវិសាមញ្ញតាមគំនិតផ្តួចផ្តើមរបស់ប្រធាន **គ.ធ.ស.** ឬតាមការស្នើសុំពីសមាជិក **គ.ធ.ស.** ចាប់ពីចំនួន២/៣( ពីរភាគបី )។

កិច្ចប្រជុំរបស់ **គ.ធ.ស.** អាចប្រព្រឹត្តទៅបានលុះត្រាតែមានវត្តមានសមាជិកលើសពី៥០(ហាសិប)ភាគរយនៃចំនួនសមាជិកសរុប។ អ្នកជំនាញការផ្នែកវិនិយោគអាចត្រូវបានអញ្ជើញឱ្យចូលរួមក្នុងកិច្ចប្រជុំដែលពាក់ព័ន្ធនឹងគម្រោងវិនិយោគរបស់ខ្លួន ប៉ុន្តែគ្មានសិទ្ធិចូលរួមក្នុងការសម្រេចចិត្តឡើយ។

**មាត្រា១១ .-**

នាយកដ្ឋានគ្រប់គ្រងការវិនិយោគមូលនិធិសន្តិសុខសង្គមនៃ **ប.ស.ស.** បំពេញមុខងារជាលេខាធិការដ្ឋានរបស់ **គ.ធ.ស.** និងត្រូវចូលរួមកិច្ចប្រជុំ **គ.ធ.ស.** ជាប្រចាំ។ លេខាធិការដ្ឋានត្រូវរៀបចំនិងផ្ញើសេចក្តីព្រាងកំណត់ហេតុជូនសមាជិក **គ.ធ.ស.** ក្នុងរយៈពេល៣( បី )ថ្ងៃ ក្រោយកាលបរិច្ឆេទនៃកិច្ចប្រជុំនីមួយៗ។ សមាជិក **គ.ធ.ស.** មានរយៈពេល៥( ប្រាំ )ថ្ងៃនៃថ្ងៃធ្វើការងារ គិតចាប់ពីកាលបរិច្ឆេទទទួលបានកំណត់ហេតុប្រជុំដើម្បីបញ្ជាក់អំពីភាពត្រឹមត្រូវ ឬផ្តល់មតិកែសម្រួលលើកំណត់ហេតុ។ ក្នុងរយៈពេល១០(ដប់)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃកិច្ចប្រជុំ ប្រធាន **គ.ធ.ស.** ត្រូវចុះហត្ថលេខាលើកំណត់ហេតុដែលទទួលបានការកែតម្រូវឬការយល់ព្រមពីសមាជិក **គ.ធ.ស.** ទាំងអស់។

**មាត្រា១២ .-**

លេខាធិការដ្ឋានរបស់ **គ.ធ.ស.** ត្រូវបញ្ជូនកំណត់ហេតុ របាយការណ៍ និងសេចក្តីសម្រេចផ្សេងៗ យ៉ាងយូរ ១៥( ដប់ប្រាំ )ថ្ងៃ ក្រោយកាលបរិច្ឆេទនៃកិច្ចប្រជុំ **គ.ធ.ស.** ជូនសមាជិក **គ.ធ.ស.** អគ្គនាយក **ប.ស.ស.** និយ័តករសន្តិសុខសង្គម និងក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស.**។

**មាត្រា១៣ .-**

ការអនុម័តពាក់ព័ន្ធនឹងគោលការណ៍វិនិយោគមូលនិធិសន្តិសុខសង្គមយកជាការបាន លុះត្រាតែកូរ៉ុមទទួលបានសំឡេងជាឯកច្ឆន្ទនៃចំនួនសមាជិកដែលមានវត្តមានក្នុងកិច្ចប្រជុំ។

ការអនុម័តពាក់ព័ន្ធនឹងហិរញ្ញវត្ថុយកជាការបាន លុះត្រាតែកូរ៉ុមទទួលបានសំឡេងភាគច្រើនដាច់ខាតនៃចំនួនសមាជិកដែលមានវត្តមានក្នុងកិច្ចប្រជុំ។

សំឡេងរបស់ប្រធានដឹកនាំអង្គប្រជុំ **គ.ធ.ស.** មានឧត្តមានុភាពក្នុងករណីសំឡេងក្នុងអង្គប្រជុំស្មើគ្នា។

**មាត្រា១៤ .-**

អគ្គនាយក **ប.ស.ស.** និយ័តករសន្តិសុខសង្គម និងក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស.** ដូចមានចែងក្នុងមាត្រា១២នៃអនុក្រឹត្យនេះ មានរយៈពេល៣០( សាមសិប )ថ្ងៃ ចំពោះកិច្ចការបច្ចេកទេសនិងកិច្ចការហិរញ្ញវត្ថុដើម្បីបដិសេធលើរបាយការណ៍ឬកំណត់ហេតុប្រជុំរបស់ **គ.ធ.ស.** ដោយអនុលោមតាមនីតិវិធីដែលមានចែងក្នុង



9

មាត្រា២៧នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥២០/៥៨២ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០ ស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គម ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល។ ក្នុងករណីពុំមានការឆ្លើយតបក្នុងរយៈពេលខាងលើនេះ ចាត់ទុកថាបានទទួលស្គាល់និងឯកភាពលើរបាយការណ៍ឬកំណត់ហេតុប្រជុំដែលបានដាក់ជូនដោយ **គ.ធ.ស.**។

ក្រសួង ឬស្ថាប័នពាក់ព័ន្ធ អាចអញ្ជើញតំណាង **គ.ធ.ស.** មកបំភ្លឺលើកិច្ចការបច្ចេកទេសនិងកិច្ចការហិរញ្ញវត្ថុក្នុងរយៈពេលមិនលើសពី៣០(សាមសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទទទួលរបាយការណ៍ឬកំណត់ហេតុនៃកិច្ចប្រជុំ។

**មាត្រា១៥ ._**

**គ.ធ.ស.** អាចអញ្ជើញតំណាងក្រសួង ស្ថាប័ន ឬអង្គភាពពាក់ព័ន្ធនានា តំណាងដៃគូអភិវឌ្ឍ តំណាងវិស័យឯកជន និងតំណាងសង្គមស៊ីវិល ដើម្បីពិភាក្សាការងារក្នុងគោលដៅជំរុញប្រសិទ្ធភាពនៃការអនុវត្តផែនការវិនិយោគតាមការចាំបាច់។

**មាត្រា១៦ ._**

**គ.ធ.ស.** មានសិទ្ធិបង្កើតគណៈកម្មការចំពោះកិច្ចលើគម្រោងវិនិយោគនីមួយៗ ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ធ.ស.**។ គណៈកម្មការនេះនឹងត្រូវបញ្ចប់ទៅវិញ ក្រោយគម្រោងវិនិយោគនីមួយៗត្រូវបានបញ្ចប់ជាស្ថាពរ។

**មាត្រា១៧ ._**

**គ.ធ.ស.** មានសិទ្ធិប្រើរូបសញ្ញានិងត្រារបស់ **ប.ស.ស.** សម្រាប់ដំណើរការការងាររបស់ខ្លួន។

**មាត្រា១៨ ._**

ការចំណាយសម្រាប់អនុវត្តភារកិច្ចរបស់ **គ.ធ.ស.** គឺជាបន្ទុករបស់ **ប.ស.ស.** ដែលកំណត់ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស.** ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៥

## ទណ្ឌកម្ម

**មាត្រា១៩ ._**

**គ.ធ.ស.** មានកាតព្វកិច្ចរក្សាការសម្ងាត់ផ្នែកវិនិយោគរបស់ **ប.ស.ស.** ទោះបីជាការវិនិយោគនោះស្ថិតនៅក្នុងដំណាក់កាលកំពុងសិក្សា ឬកំពុងអនុវត្តគម្រោងវិនិយោគក៏ដោយ។ ក្នុងករណីដែលបុគ្គលណាម្នាក់ទម្លាយការសម្ងាត់ផ្នែកវិនិយោគរបស់ **ប.ស.ស.** ឱ្យតតិយជនដឹងដោយគ្មានការអនុញ្ញាត បុគ្គលនោះត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**មាត្រា២០ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២១ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១២រោច ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**ហេង សួរ**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ